ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តធម៌នៅកម្ពុជា
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA

# ការស្ទង់មតិ

# ការចូលរួមរបស់
# សកម្មជននយោបាយស្ត្រី
# នៅក្នុងវិស័យនយោបាយនៅកម្ពុជា



ខែធ្នូ ឆ្នាំ២០២០

# ការស្ទង់មតិ

# ការចូលរួមរបស់
# សកម្មជននយោបាយស្ត្រី
# នៅក្នុងវិស័យនយោបាយនៅកម្ពុជា

អ្នកស្រាវជ្រាវ

**បណ្ឌិត ប៉ា ចន្ទរឿន & បណ្ឌិត សេង សារី**

# មាតិកា


I. លំនាំដើម……………………………………………………………………………….3

II. កម្មវត្ថុ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ………………………………………..4

III. វិធីសាស្ត្រនៃការសិក្សាស្ទង់មតិ…………………………………………………………..5

IV. លទ្ធផលនៃការស្រាវជ្រាវ និងការវិភាគ……………………………………………..8

4.1 លទ្ធផលពីការសិក្សាវិភាគឯកសារ……………………………………………...8

4.2 លទ្ធផលពីការស្ទង់មតិ…………………………………………………………………..15

V. សេចក្តីសន្និដ្ឋាន…………………………………………………………………………..28

VI. អនុសាសន៍គន្លឹះ………………………………………………………………………..30

# I. លំនាំដើម

ស្ថានភាពនយោបាយនៅកម្ពុជាមានការផ្លាស់ប្តូរយ៉ាងខ្លាំង ជាពិសេសក្នុងអំឡុងពេលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ រួមទាំងការរួមកាន់តែតូចនៃលំហប្រជាធិបតេយ្យសម្រាប់ពលរដ្ឋ ការបិទប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ការរឹតត្បិតនិងការបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសង្គមស៊ីវិល ដែលត្រូវបានមើលឃើញថាជាឧបសគ្គដ៏ខ្លាំងក្នុងចលនារយៈពេលវែងរបស់អង្គការសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍរួម និងក្រោយការរំលាយគណបក្សប្រឆាំងដ៏ធំ (គណបក្សសង្គ្រោះជាតិកម្ពុជា-CNRP) អ្នកនយោបាយស្ត្រី និងសកម្មជននយោបាយនៃគណបក្សប្រឆាំងដ៏ធំនេះត្រូវបានគេបោះបង់ចោល និងរារាំងមិនឱ្យចូលរួមក្នុងដំណើរការនយោបាយ និងការបោះឆ្នោត ជាពិសេសការហាមឃាត់ស្ត្រីអ្នកនយោបាយប្រឆាំងចូលរួមក្នុងការបោះឆ្នោត ឆ្នាំ២០១៨ បរិយាកាសប្រកបដោយការភ័យខ្លាច និងការរឹតត្បិតចំពោះសេរីភាពបញ្ចេញមតិរបស់ពួកគេ។ លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ បានកត់សម្គាល់ពីជំហានថយក្រោយនៃដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ដោយផ្លាស់ប្តូរពីពហុនិយមនយោបាយទៅជាការគ្រប់គ្រងដោយឯកបក្ស (គណបក្សប្រជាជនកម្ពុជា) ដោយទទួលបានជ័យជំនះក្នុងការបោះឆ្នោតទាំងស្រុងដែលឈានដល់ការគ្រប់គ្រងនីតិប្បញ្ញត្តិ និងតុលាការ។ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបានចោទជាសំណួរអំពី "ភាពត្រឹមត្រូវ" នៃការបោះឆ្នោតសាកលនៅខែកក្កដា ឆ្នាំ២០១៨ ដែលគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចបានឈ្នះអាសនៈសភាទាំងអស់នៅក្នុងការបោះឆ្នោត។ ការធាក់ថយក្រោយនៃពហុនិយមនយោបាយធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់គុណភាពនៃការចូលរួមរបស់ស្ត្រី និងស្ត្រីជាប់ឆ្នោត។ ពហុនិយមនយោបាយនៃយេនឌ័រគឺជាធាតុសំខាន់មួយក្នុងការធានាការត្រួតពិនិត្យ និងតុល្យភាពយេនឌ័រផ្នែកនយោបាយ។

The International Knowledge Network of Women in Politics (iKNOW Politics) រាយការណ៍ថា ស្ត្រីរងគ្រោះខ្លាំងជាងគេដោយសារជំងឺរាតត្បាតកូវីដ១៩ នាពេលបច្ចុប្បន្ន។ លើសពីផលប៉ះពាល់ដោយផ្ទាល់នៃការឆ្លងដោយវីរុសកូរ៉ូណា សុខភាព និងសុវត្ថិភាពរបស់ស្ត្រីមានហានិភ័យខ្ពស់ដោយសារ  អត្រានៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានលើស្ត្រីបានកើនឡើង ហើយសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជត្រូវបានកាត់បន្ថយ។ នៅក្នុងវិបត្តិដែលមិនធ្លាប់មានពីមុនមកបែបនេះ ស្ត្រីក៏ប្រឈមនឹងការកើនឡើងនៃបន្ទុកក្នុងការថែទាំ និងហានិភ័យនៃការឈឺដោយសារពួកគេភាគច្រើនគឺជាបុគ្គលិកថែទាំសុខភាពជួរមុខ និងអ្នកថែទាំអ្នកជំងឺនៅតាមផ្ទះ និងសហគមន៍នៅទូទាំងពិភពលោក។ បញ្ហាទាំងអស់នេះបានបន្ថែមផលប៉ះពាល់ដោយប្រយោលនៃជំងឺរាតត្បាតទៅលើជីវភាពរស់នៅរបស់ស្ត្រីគ្រប់ទីកន្លែង។[1]

[1] E-Discussion on Women's Leadership in the COVID-19 Response, iKNOW Politics, 2020

ដោយសារបញ្ហាប្រឈមទាំងនេះ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានរៀបចំការសិក្សាស្រាវជ្រាវស្តីពី «ការចូលរួមរបស់សកម្មជនស្ត្រីនយោបាយនៅក្នុងវិស័យនយោបាយ» ដើម្បីឈ្វេងយល់ថាតើស្ត្រីមានឆន្ទៈចូលរួមក្នុងនយោបាយ/ការបោះឆ្នោតឬទេនៅក្នុងរយៈពេល ២ឆ្នាំ ឬ ៣ឆ្នាំខាងមុខ។ ការសិក្សានេះផ្អែកលើជំនឿរបស់ខុមហ្វ្រែលថា សង្គមមួយដែលត្រឹមត្រូវ និងមានប្រជាធិបតេយ្យទាមទារឱ្យមានការចូលរួមពីសង្គម និងនយោបាយរបស់ក្រុមសង្គមទាំងអស់រួមទាំងស្ត្រី ជាពិសេសសកម្មជននយោបាយស្ត្រី។

## II. គម្រោង និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

### គម្រោងចម្បងនៃការសិក្សាស្រាវជ្រាវនេះគឺ៖

1) បង្ហាញឱ្យឃើញនូវការយល់ឃើញ និងទស្សនៈរបស់ស្ត្រីក្នុងការចូលរួមក្នុងនយោបាយក្នុងបរិបទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ រួមមានស្ថានភាពក្រោយការបោះឆ្នោត និងផលប៉ះពាល់នៃការរាតត្បាតជំងឺកូវីដ១៩ និងធ្វើការប៉ាន់ស្មានអំពីការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយនាពេលអនាគត។
2) ដើម្បីឈ្វេងយល់ឱ្យកាន់តែច្បាស់អំពីធម្មជាតិ សញ្ញាណ និងបុព្វហេតុនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីដែលធ្វើនយោបាយនៅកម្ពុជា។
3) ផ្តល់ជាស៊េរីនៃអនុសាសន៍អំពីវិធីដែលគណបក្សនយោបាយ ស្ថាប័នសាធារណៈ និងអង្គការសង្គមស៊ីវិលអាចកាត់បន្ថយអំពើហឹង្សាប្រឆាំងនឹងស្ត្រីដែលសកម្មក្នុងនយោបាយ។
4) រៀបចំផែនការសកម្មភាពដើម្បីលុបបំបាត់អំពើហឹង្សាលើស្ត្រីក្នុងនយោបាយដើម្បីឱ្យស្ត្រីកាន់តែច្រើនចូលរួមក្នុងដំណើរការនយោបាយដោយគ្មានការភ័យខ្លាច។

### វិសាលភាពនៃការសិក្សាស្ទង់មតិ

ការសិក្សាស្រាវជ្រាវនេះបានធ្វើជាមួយមនុស្ស១០០នាក់មកពីគណបក្សនយោបាយចំនួន ២០ ដែលតំណាងឱ្យអ្នកនយោបាយដែលបម្រើការនៅក្នុងរដ្ឋាភិបាល គណបក្សប្រឆាំង និងអតីតគណបក្សប្រឆាំងធំក៏ដូចជាមេដឹកនាំស្ត្រីរបស់អង្គការសង្គមស៊ីវិល (CSO) បានស្ម័គ្រចិត្តចូលរួមក្នុងការស្ទង់មតិនេះ។

# III. វិធីសាស្ត្រនៃការសិក្សាស្ទង់មតិ

ដើម្បីសម្រេចវត្ថុបំណងនៃការសិក្សាស្ទង់មតិនេះ មានទាំងវិធីសាស្ត្រគុណវិស័យនិងបរិមាណវិស័យដែលរួមមានការសិក្សាវិភាគឯកសារ ការស្ទង់មតិ និងការសម្ភាសអ្នកជំនាញនិងការពិភាក្សាជាក្រុម។

## 3.1 ការសិក្សាវិភាគឯកសារ

វិធីនេះពិនិត្យមើលឯកសារដែលមានស្រាប់ដូចជារបាយការណ៍ គោលនយោបាយ ច្បាប់ និង គម្រោងដែលមានស្រាប់ទាក់ទងនឹងការចូលរួមរបស់សកម្មជននយោបាយស្ត្រីនៅក្នុងនយោបាយនៅកម្ពុជា។ វត្ថុបំណងសំខាន់នៃការសិក្សាពិនិត្យឯកសារនេះ គឺដើម្បីបង្ហាញពីគោលនយោបាយ ច្បាប់ និង ការសិក្សាដែលទាក់ទងនឹងការស្ទង់មតិនេះ។ ដំណាក់កាលនេះជាផ្នែកមួយដែលនឹងត្រូវយកទៅប្រើប្រាស់សម្រាប់បង្កើតកម្រងសំណួរ និងប្រធានបទសំខាន់ៗសម្រាប់ការសម្ភាសស៊ីជម្រៅជាមួយភាគីពាក់ព័ន្ធទាំងអស់។

## 3.2 ការប្រមូលទិន្នន័យចំបង

ទិន្នន័យចំបងដែលប្រមូលបានតាមរយៈការស្ទង់មតិ ការសម្ភាសអ្នកជំនាញ និងការពិភាក្សាជាក្រុម។ កម្រងសំណួរនៃការស្ទង់មតិ និងកម្រងសំណួរសម្រាប់ការសម្ភាសត្រូវបានព្រាងដោយផ្អែកលើវត្ថុបំណងនៃការសិក្សា។ សំណាកនៃការស្ទង់មតិត្រូវបានជ្រើសរើស និងកំណត់ដូចខាងក្រោម៖

| វិធីសាស្ត្រ | ចំនួនអ្នកចូលរួមការសិក្សា | ទីតាំង |
|---|---|---|
| ការស្ទង់មតិ | អ្នកចូលរួមចំនួន ៥៥នាក់ (បុរស ១៥នាក់ និង ស្ត្រី ៤០នាក់) នៃក្រុមគោលដៅមកពី គណបក្សចំនួន ២០ (មនុស្ស ៣នាក់មកពីគណបក្សនីមួយៗ) មេដឹកនាំជាបុរស អ្នកដឹកនាំជាស្ត្រី សមាជិកសភាជាស្ត្រី ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ សកម្មជននយោបាយស្ត្រី និងជាអ្នកដឹកនាំអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងស្ត្រីក្នុងនយោបាយ និងអំណាចនៃការធ្វើសេចក្តីសម្រេចចិត្ត។ | ▪ មនុស្ស ៣៥នាក់ នៅទីក្រុងភ្នំពេញ<br>▪ មនុស្ស ១០នាក់នៅខេត្តកំពង់ឆ្នាំង<br>▪ មនុស្ស ១០នាក់នៅខេត្តបាត់ដំបង |

| | | |
|---|---|---|
| ការសម្ភាស អ្នកជំនាញ | - ការសម្ភាសជាមួយបុគ្គលសំខាន់ៗចំនួន ១១ នាក់ជាមួយនឹងអ្នកនយោបាយស្ត្រីដើម្បីឱ្យពួកគេចែករំលែកអំពីភាពជោគជ័យ និងការប្រឈមផ្ទាល់ខ្លួនដ៏ធំបំផុតក្នុងអំឡុងពេលនៃភាពសកម្មរបស់ពួកគេនៅក្នុងគណបក្សនយោបាយ ការជ្រើសតាំងជាសមាជិកសភា និងនៅថ្នាក់ក្រោមជាតិ។<br>- ជាមួយមេដឹកនាំអង្គការក្រៅរដ្ឋាភិបាល៣នាក់ និងអ្នកពិគ្រោះយោបល់ផ្នែកយេនឌ័រម្នាក់ (អង្គការ COMFREL, SILAKA, GADC និង ទីប្រឹក្សាយេនឌ័រ) | - មនុស្ស ១១នាក់នៅទីក្រុងភ្នំពេញ<br>- មនុស្ស ២នាក់នៅខេត្តកំពង់ឆ្នាំង<br>- មនុស្ស ២នាក់នៅខេត្តបាត់ដំបង |
| ការពិភាក្សាជាក្រុម | ការពិភាក្សាជាក្រុមចំនួន ៨ (មនុស្ស ៣០នាក់) ជាមួយសកម្មជនស្ត្រីរបស់គណបក្សនយោបាយ។ ក្នុងការពិភាក្សានីមួយៗមានអ្នកចូលរួមពី ៣នាក់ ទៅ ៦នាក់។ | ▪ ការពិភាក្សាជាក្រុមចំនួន ៤ នៅក្នុងទីក្រុងភ្នំពេញ<br>▪ ការពិភាក្សាជាក្រុមចំនួន ២ នៅក្នុងខេត្តកំពង់ឆ្នាំង<br>▪ ការពិភាក្សាជាក្រុមចំនួន ២ នៅខេត្តបាត់ដំបង |

ការសម្ភាសជាមួយអ្នកជំនាញផ្តោតសំខាន់លើការកត់ត្រាយោបល់ និងទស្សនៈផ្ទាល់ខ្លួនអំពីប្រធានបទដែលត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់ពីស្ថានភាពបច្ចុប្បន្ននៃការចូលរួមរបស់ស្ត្រីក្នុងនយោបាយនៅកម្ពុជា។ បទសម្ភាសន៍ត្រូវបានធ្វើឡើងជាភាសាខ្មែរ។ ដើម្បីទទួលបានលទ្ធផលមានកម្រិតនៃភាពជឿជាក់ និងភាពយកជាការបានខ្ពស់ សំណួរ និងមគ្គុទ្ទេសក៏នៃការសម្ភាសត្រូវបានយកទៅសាកល្បងដើម្បីពិនិត្យពីភាពត្រឹមត្រូវ ការប្រើប្រាស់ពាក្យពេចន៍ និងភាពងាយស្រួលយល់មុនពេលធ្វើសម្ភាសជាផ្លូវការ។

## 3.3 ការកត់ត្រា និងវិភាគទិន្នន័យ

រាល់ការពិភាក្សា និងការសម្ភាសត្រូវបានកត់ត្រាដោយមានការយល់ព្រមពីអ្នកចូលរួម។ អ្នកកត់ត្រាបានសង្កេតការពិភាក្សា ធ្វើការកត់ត្រាអំពីការឆ្លើយតប ការបញ្ចេញមតិ និងការប្រាស្រ័យទាក់ទងតាម

វេយៈកាយវិការ និងអារម្មណ៍ ព្រមទាំងសំណួរនៃពាក្យពេចន៍របស់អ្នកចូលរួមការពិភាក្សា។ សារជាសំឡេងនៃការពិភាក្សាត្រូវបានបំលែងជាអក្សរ ហើយបន្ទាប់មកទិន្នន័យត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធី MS Excel ដើម្បីដាក់លេខកូដ សម្អាតទិន្នន័យ និងពិនិត្យមើលភាពត្រឹមត្រូវមុនពេលបញ្ចេញទិន្នន័យ និងធ្វើការវិភាគ។ លទ្ធផលត្រូវបានបែងចែកជាជំពូក ប្រធានបទ និងបញ្ហាអាទិភាព។

- ចម្លើយពីការស្ទង់មតិ ការពិភាក្សាជាក្រុម និងការសម្ភាសស៊ីជម្រៅ ដកស្រង់បានជាប្រធានបទគន្លឹះ និងរៀបចំជារបាយការណ៍ និងផែនការសកម្មភាពនៃគណបក្សនយោបាយដែលបានចូលរួម។
- ប្រមូលផ្តុំការឆ្លើយតបទៅគ្រប់គណបក្សទាំងអស់ និងទុកជាឯកសារសាធារណៈដែលលើកបញ្ហាអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងគណបក្សនយោបាយ និងផលប៉ះពាល់របស់វាទៅលើភាពស្មើគ្នា។
- ការវាយតម្លៃផ្តោតលើបុព្វហេតុ (ឬសគល់បញ្ហា)បីយ៉ាងនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយដោយសារមូលហេតុៈ បទដ្ឋានវប្បធម៌-សង្គម ច្បាប់ និងគោលនយោបាយ និងស្ថាប័ន។

## 3.4 ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

អ្នកសម្ភាស និងសមាជិកក្រុមការងារទាំងអស់ត្រូវបានបណ្តុះបណ្តាលអំពីបញ្ហាក្រមសីលធម៌រួមទាំងការរក្សាការសម្ងាត់ និងអនាមិកភាពរបស់អ្នកចូលរួមការសិក្សា។ អ្នកចូលរួមការសិក្សា (អ្នកឆ្លើយការស្ទង់មតិ) ដែលបានជ្រើសរើសទាំងអស់ត្រូវបានជូនដំណឹងអំពីការសិក្សានេះ ហើយបានស្នើសុំការព្រមព្រៀងពីអ្នកចូលរួមមុនចូលរួមក្នុងការសិក្សានេះ។ ដើម្បីទទួលបានការការព្រមព្រៀងត្រឹមត្រូវ ការស្ទង់មតិនេះបានប្រើប្រាស់សេចក្តីណែនាំនៅពេលចាប់ផ្តើមការសម្ភាស និងការស្ទង់មតិដើម្បីសុំការអនុញ្ញាតពីអ្នកចូលរួម និងដើម្បីធានានូវអនាមិកភាព និងការសម្ងាត់នៃការសិក្សា។ អ្នកឆ្លើយសំណួរអាចរំលងសំណួរ ឬដកខ្លួនចេញពីការសិក្សាបានគ្រប់ពេល។ មិនមានការកំណត់អត្តសញ្ញាណព័ត៌មានរបស់អ្នកឆ្លើយតបនៅក្នុងទិន្នន័យដែលត្រូវបានប្រើក្នុងការវិភាគឡើយ។ លេខអត្តសញ្ញាណត្រូវបានប្រើជំនួសឈ្មោះអ្នកចូលរួមលើសំណុំទិន្នន័យ។ រាល់កម្រងសំណួរដែលបានបំពេញនឹងត្រូវរក្សាទុកក្នុងកន្លែងមានសុវត្ថិភាពក្នុងពេលប្រមូលទិន្នន័យ បញ្ចូលទិន្នន័យ និងការវិភាគទិន្នន័យ។ មានតែអ្នកដែលទទួលខុសត្រូវក្នុងការបញ្ចូល និងវិភាគទិន្នន័យប៉ុណ្ណោះដែលអាចចូលមើលកម្រងសំណួរ និងឯកសារដ៏ទៃទៀតនៃការសិក្សានេះ។ កម្រងសំណួរត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ហើយឯកសារកុំព្យូទ័រត្រូវបានរក្សាទុកជាការសម្ងាត់។

# IV. លទ្ធផលនៃការស្រាវជ្រាវ និងការវិភាគ

## 4.1 លទ្ធផលពីការសិក្សាវិភាគឯកសារ

អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយនៅតែជាឧបសគ្គដ៏ធំបំផុតមួយសម្រាប់ការចូលរួមក្នុងនយោបាយរបស់ស្ត្រី។ ស្ត្រីនៅពាសពេញពិភពលោកត្រូវរងការគំរាមកំហែង ការធ្វើទុក្ខបុកម្នេញ ការបដិសេធគាំទ្រផ្នែកធនធាន ការរំលោភបំពាន និងការសម្លាប់ជីវិតដោយសារតែការអនុវត្តសិទ្ធិរបស់ពួកគេក្នុងការចូលរួមក្នុងដំណើរការនយោបាយ។[2]

### តើអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយជាអ្វី?

*«អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ សំដៅលើគ្រប់ទម្រង់នៃប្រទូស្តរ៉ាយ ការបង្ខិតបង្ខំ និងការបំភិតបំភ័យលើស្ត្រីក្នុងនាមជាតួអង្គនយោបាយដោយសារតែពួកគេជាស្ត្រី។»*

វិទ្យាស្ថានជាតិប្រជាធិបតេយ្យ

អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ គឺមានជាទូទៅនៅអាស៊ីខាងត្បូង នេះបើយោងតាមការស្រាវជ្រាវថ្មីមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលស្រាវជ្រាវសង្គម និងស្ត្រីរបស់អង្គការសហប្រជាជាតិ (UN Women)។ ការសិក្សា «**អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ**» បានបង្ហាញថា ការអនុវត្តច្បាប់មិនគ្រប់គ្រាន់  កង្វះការគាំទ្រពីប៉ូលីស និងតុលាការ ការបែងចែកសេដ្ឋកិច្ច-សង្គម និងរចនាសម្ព័ន្ធអំណាចបច្ចុប្បន្ន គឺជាមូលហេតុចំបងនៃអំពើហឹង្សា។[3]

យោងតាមវិទ្យាស្ថានប្រជាធិបតេយ្យជាតិ (NDI) អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយរួមមានគ្រប់ទម្រង់នៃការបំពារបំពាន ការបង្ខិតបង្ខំ និងការបំភិតបំភ័យលើស្ត្រីក្នុងនាមជាតួអង្គនយោបាយ

[2] UN Women's study conducted in India, Nepal and Pakistan, occurred from 2003 to 2013

[3] UN Women's study conducted in India, Nepal and Pakistan, occurred from 2003 to 2013

ដោយសារតែពួកគេជាស្ត្រី។ [4] សកម្មភាពទាំងនេះ - មិនថាសំដៅទៅលើស្ត្រីក្នុងនាមជាមេដឹកនាំសង្គមស៊ីវិល អ្នកបោះឆ្នោត សមាជិកគណបក្សនយោបាយ បេក្ខជន តំណាងជាប់ឆ្នោត ឬមន្ត្រីដែលត្រូវបានតែងតាំង--ត្រូវបានគេរឹតត្បិតការចូលរួមផ្នែកនយោបាយរបស់ស្ត្រីជាក្រុម។ អំពើហឹង្សានេះបានពង្រឹងនូវគោលជំហរបែបប្រពៃណី និងតួនាទី (traditional stereotypes and roles)ដែលផ្តល់ឱ្យស្ត្រីដោយប្រើការត្រួតត្រា និងការគ្របសង្កត់ដើម្បីដកស្ត្រីចេញពីឆាកនយោបាយ។

អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ សំដៅទៅលើការរើសអើងប្រឆាំងនឹងស្ត្រី កង្វះគោលការណ៍ជាក់លាក់ជាលាយលក្ខណ៍អក្សរដែលជាវិធានការពិសេស និងកង្វះនៃច្បាប់ឆ្លើយតបយេនឌ័រ ជាពិសេសច្បាប់បោះឆ្នោត កង្វះការប្រតិបត្តិឱ្យបានតឹងរ៉ឹង និងមានប្រសិទ្ធភាពនៃគោលនយោបាយ និងយន្តការដែលមានស្រាប់ក្នុងការគាំទ្រ និងផ្តល់ឱកាសស្មើគ្នាសម្រាប់ស្ត្រីនៅក្នុងនយោបាយ ការអនុវត្តមិនបានពេញលេញនូវអនុសញ្ញាអន្តរជាតិស៊ី-ដ និងរចនាសម្ព័ន្ធអំណាចបច្ចុប្បន្ន គឺជាមូលហេតុចំបងៗនៃអំពើហឹង្សា។[5]

អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ គឺជាអំពើហឹង្សាដែលកើតឡើងនៅក្នុងវិស័យនយោបាយដែលស្ត្រីជាគោលដៅ។ វាត្រូវបានប្រើដើម្បីពង្រឹងរចនាសម្ព័ន្ធសង្គម និងនយោបាយតាមបែបប្រពៃណីដោយសំដៅលើមេដឹកនាំស្ត្រីដែលតតាំងនឹងបិតាធិបតេយ្យ និងគ្របដណ្តប់ការរំពឹងទុកនិងបទដ្ឋានសង្គមដែលបានអនុវត្តកន្លងមក។ វារឹតត្បិតចលនា និងសមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមក្នុងវិស័យនយោបាយ។ អំពើហឹង្សាបែបនេះអាចប្រព្រឹត្តដោយអ្នកនយោបាយ សង្គម និងរដ្ឋ។

## តើអ្វីទៅជាទម្រង់ទូទៅនៃអំពើហឹង្សាប្រឆាំងស្ត្រីនៅក្នុងឆាកនយោបាយ?

សញ្ញាណនៃអំពើហឹង្សាចំពោះស្ត្រីដែលសកម្មក្នុងនយោបាយ ត្រូវបានចាត់ថ្នាក់ជាប្រភេទដូចជា ផ្លូវចិត្ត រាងកាយ ផ្លូវភេទ និងសេដ្ឋកិច្ចដែលមានលក្ខណៈពិសេសប្លែកនៅពេលអនុវត្តលើជីវិតនយោបាយ៖

### អំពើហឹង្សាផ្លូវចិត្ត

**អំពើហឹង្សាផ្លូវចិត្ត** សំដៅទៅលើការរំលោភបំពានដោយពាក្យសំដី និងអារម្មណ៍ និងសកម្មភាពដែលមានគោលបំណងធ្វើឱ្យអន្តរាយដល់តម្លៃ និង/ឬសន្តិសុខ និងសុវត្ថិភាពផ្ទាល់ខ្លួន។ សកម្មភាពទាំងនោះរាប់បញ្ចូលទាំងការបរិហារកេរ្តិ៍ ការបង្កាច់បង្ខូច ការវាយប្រហារ ការយាយីតាមប្រព័ន្ធផ្សព្វផ្សាយ ការ

---

[4] National Democratic Institute. Stopping Violence Against Women in Politics: Program Guidance.
[5] COMFREL’s report on the Empowerment of Women in Politics and Local and National Elections 2017, 2018

យាយីតាមអ៊ីនធឺណិត/បណ្តាញផ្សព្វផ្សាយសង្គម ការដៅឈ្មោះ ការជេរប្រមាថ ការប្រើប្រាស់ពាក្យអសុរោះ ការរិះគន់ឥតឈប់ឈរ និង/ឬការផ្តោតលើរូបរាង។ អំពើហឹង្សាផ្លូវចិត្ត ក៏អាចរួមបញ្ចូលទាំងសកម្មភាពដែលធ្វើឱ្យមានការភ័យខ្លាច ឬបង្កើតឱ្យមានភាពឯកោ ដូចជា ការគំរាមកំហែងនៃការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ និងទម្រង់នៃការតាមដានឃ្លាំមើល។ ជាក់ស្តែង បន្ទាប់ពីគណបក្សសង្គ្រោះជាតិកម្ពុជាត្រូវបានរំលាយនៅ ខែវិច្ឆិកា ឆ្នាំ២០១៧ អតីតសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់គណបក្សសង្គ្រោះជាតិជាច្រើននាក់ត្រូវទទួលរងការរំលោភបំពានផ្នែកនយោបាយ រួមមានឧប្បត្តិហេតុនៃការវាយប្រហារលើរាងកាយ ការគំរាមសម្លាប់ ការបាត់បង់ជីវភាពសេដ្ឋកិច្ច និងការរំលោភបំពានដោយពាក្យសំដី និងផ្លូវចិត្ត។[6]

## អំពើហឹង្សាលើរាងកាយ

**អំពើហឹង្សាលើរាងកាយ**រួមបញ្ចូលទាំងការធ្វើឱ្យរងរបួសដែលបង្កឡើងដោយផ្ទាល់ទៅលើស្ត្រីក៏ដូចជាការធ្វើបាបរាងកាយលើសាច់ញាតិរបស់ពួកគេ មានជាអាទិ៍ ការវាយធ្វើបាបលើរាងកាយ ការសម្លាប់ ការចាប់ពង្រត់ ការវាយដំ និងការរំលោភបំពានក្នុងគ្រួសារដែលមានគោលបំណងរារាំង ឬធ្វើឱ្យអន្តរាយដល់ការចូលរួមនយោបាយរបស់ស្ត្រី។ នេះជាឧទាហរណ៍មួយពីប្រទេសបូលីវី (Bolivia)ក្នុងឆ្នាំ២០១០ លោកស្រី Juana Quispe ត្រូវបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ហើយនៅពេលដែលលោកស្រីចូលកាន់តំណែងបានរងការធ្វើបាបដោយសមាជិកក្រុមប្រឹក្សារបស់លោកស្រី។ លោកស្រីបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាច្រើនប្រឆាំងនឹងការរំលោភបំពានលើរាងកាយ និងពាក្យសំដីដែលបានបញ្ជាក់ថា ពួកគេមិនអនុញ្ញាតឱ្យលោកស្រីអនុវត្តសិទ្ធិនយោបាយរបស់លោកស្រីទេ ហើយលោកស្រីត្រូវបានគេដកចេញពីតំណែង។ ៣២ថ្ងៃបន្ទាប់ពីទទួលបានសិទ្ធិនយោបាយឡើងវិញក្នុងនាមជាក្រុមប្រឹក្សា លោកស្រីត្រូវបានគេធ្វើឃាត។ ករណីនេះ រួមជាមួយពាក្យបណ្តឹងជាច្រើនទៀតរបស់ស្ត្រីនៅក្នុងការិយាល័យសាធារណៈ បានធ្វើឱ្យមានការអនុម័តច្បាប់ប្រឆាំងនឹងការយាយី និងអំពើហឹង្សានយោបាយចំពោះស្ត្រី (លេខ២៤៣) ក្នុងឆ្នាំ២០១២។[7]

## អំពើហឹង្សាផ្លូវភេទ

**អំពើហឹង្សាផ្លូវភេទ** រួមមានទង្វើផ្លូវភេទ និងការប៉ុនប៉ងធ្វើអំពើផ្លូវភេទដោយការបង្ខិតបង្ខំ ឬដោយកម្លាំងក៏ដូចជាការបញ្ចេញមតិផ្លូវភេទដែលមិនសមរម្យ និងការយាយីផ្លូវភេទ។ ឧទាហរណ៍ រួមមានការរំលោភសេពសន្ថវៈ/ការរួមភេទដោយមិនមានការព្រមព្រៀង ការយាយីផ្លូវភេទ ទំនាក់ទំនងផ្លូវភេទដែល

---

[6] https://www.rfa.org/english/news/cambodia/beaten-12142020172604.html
[7] Franz Chavez, 2009. “BOLIVIA: Politics, a Risky Business for Women,” *Inter Press Service*, 27 October. For more information, please consult page 35 of the Programming Guide.

មិនមានការព្រមព្រៀង ការប៉ុនប៉ងបង្ខំស្ត្រីឱ្យធ្វើសកម្មភាពផ្លូវភេទជាថ្នូរនឹងលទ្ធផលនយោបាយ ដូចជាការជានាការតែងតាំង ការផ្តល់មូលនិធិ ឬលទ្ធផលនៃការបោះឆ្នោត។ នៅប្រទេសអូស្ត្រាលី បទពិសោធរបស់អតីតនាយករដ្ឋមន្ត្រីលោកស្រី Julia Gillard ជាឧទាហរណ៍នៃការរំលោភបំពានផ្លូវភេទដែលស្ត្រីទទួលរងនៅក្នុងជីវិតការងារសាធារណៈ។ នៅក្នុងសុន្ទរកថារបស់លោកស្រីស្តីពី «ភេទនិយម និងការស្អប់ស្ត្រី» នៅក្នុងរដ្ឋសភាក្នុងឆ្នាំ២០១២ លោកស្រី Gillard ព្រមានថា ស្ត្រីអាចនឹងទទួលរងការគំរាមកំហែងនៃអំពើហឹង្សា ឬការរំលោភសេពសន្ថវៈស្ទើរតែរាល់ថ្ងៃ។ ក្នុងឆ្នាំ២០១៦ លោកស្រី Julia Gillard បានឆ្លុះបញ្ចាំងថា «ខ្ញុំគិតថា បញ្ហានេះទាក់ទងនឹងភេទនិយម និងជាពិសេសភេទនិយដែលវាប្រឈមមុខនឹងមេដឹកនាំស្ត្រី--ឥឡូវនេះវាគឺជាបញ្ហាមួយនៅក្នុងការសន្ទនាជាសកលនៅសម័យកាលរបស់យើង។[8]

## អំពើហឹង្សាផ្នែកសេដ្ឋកិច្ច

**អំពើហឹង្សាផ្នែកសេដ្ឋកិច្ច** ពាក់ព័ន្ធនឹងឥរិយាបទបង្ខិតបង្ខំ ឬប្រើប្រាស់កម្លាំងដើម្បីគ្រប់គ្រងការទទួលបានធនធានសេដ្ឋកិច្ច ការប្រើប្រាស់ប្រាក់ដើម្បីគ្រប់គ្រងស្ត្រី ការបដិសេធ និងការពន្យារពេលធនធានដែលមានសម្រាប់ពួកគេ និងការបំផ្លាញទ្រព្យសម្បត្តិ។ ឧទាហរណ៍អ្នកបោះឆ្នោតស្ត្រីមួយចំនួនអាចត្រូវបានគេបដិសេធមិនផ្តល់ថវិកា ឬធនធានផ្សេងទៀតឱ្យដើម្បីបង្ខិតបង្ខំការបោះឆ្នោតរបស់ពួកគេ ឬរារាំងពួកគេមិនឱ្យបោះឆ្នោត។ ក្នុងករណីខ្លះ អ្នកនយោបាយជាស្ត្រីអាចត្រូវបានគេបដិសេធមិនផ្តល់ហិរញ្ញវត្ថុ សម្ភារ ឬធនធានសេដ្ឋកិច្ចផ្សេងទៀតដែលពួកគេមានសិទ្ធិទទួលបានតាមច្បាប់ ជាញឹកញាប់សម្រាប់គោលបំណងបោះឆ្នោត ឬមណ្ឌលបោះឆ្នោត ហើយវាអាចរកបានសម្រាប់សមភាគីបុរសរបស់ពួកគេ។

នៅទូទាំងពិភពលោក ស្ត្រីដែលធ្វើសកម្មភាពនយោបាយ ជាអ្នកបោះឆ្នោត សកម្មជននយោបាយ បេក្ខជន សមាជិកក្រុមប្រឹក្សាមូលដ្ឋាន សមាជិកសភា សកម្មជនសហគមន៍ អ្នកសរសេរប្លុកជាដើម តែងតែប្រឈមមុខនឹងបញ្ហា ឬការគំរាមកំហែងនៃអំពើហឹង្សា។ ការកើនឡើងនូវអំពើហឹង្សាប្រឆាំងនឹងស្ត្រីបានក្លាយជាឧបសគ្គដ៏ធំដល់ស្ត្រីក្នុងការទទួលបានសិទ្ធិរបស់ខ្លួនក្នុងការចូលរួមដោយពេញលេញ និងស្មើភាពនៅក្នុងឆាកនយោបាយ និងជីវិតការងារសាធារណៈ។ មិនមានការបដិសេធថាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ការកើនឡើងនៃអ្នកតំណាងនយោបាយរបស់ស្ត្រីត្រូវបានអមដោយការកើនឡើងនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងនយោបាយផងដែរ។

[8] John Morgan, 2016. “Julia Gillard on tackling sexism against female leaders.” *Times Higher Education*. https://www.timeshigheredu cation.com/features/julia-gillard-on-tackling-sexism-against-female- leaders.

## និន្នាការទូទៅនៃការចូលរួមនយោបាយរបស់ស្ត្រីនៅកម្ពុជា

នៅប្រទេសកម្ពុជា ស្ត្រីបានចូលរួមកាន់តែច្រើននៅក្នុងវិស័យនយោបាយ ហើយស្ត្រីបានចូលរួមយ៉ាងសកម្មនៅក្នុងការបោះឆ្នោតក្នុងទសវត្សថ្មីៗនេះទាក់ទងនឹង ការបោះឆ្នោត សំឡេង និងសកម្មភាពនយោបាយ។ ផ្ទុយទៅវិញ ឱកាសដែលស្ត្រីទទួលបានមានតិចតួចក្នុងការឈរឈ្មោះជាបេក្ខជន និងបានជាប់ឆ្នោតជាអ្នកដឹកនាំ។ មានការថយចុះចំនួនស្ត្រីជាប់ឆ្នោតជាបន្តបន្ទាប់រាប់ចាប់ពីនីតិកាលទី៥ ឆ្នាំ២០១៣ ដល់នីតិកាលទី៦ ឆ្នាំ២០១៨ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចំណែកឯបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតនៅតែមានចំនួនតិចនៅឡើយ គឺ ២៥,២៥% នៃនីតិកាលទី៦។

នៅក្នុងនីតិកាលទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងកិច្ចការនារីបន្តផ្តោតលើការអភិវឌ្ឍធនធានមនុស្ស ជាពិសេសលើជំនាញភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យនយោបាយ សង្គម និងសេដ្ឋកិច្ចនៅថ្នាក់ជាតិ ក៏ដូចជាការផ្តល់សិទ្ធិអំណាចដល់ស្ត្រីដើម្បីទទួលបានជោគជ័យក្នុងអាជីវកម្ម។ សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងកុមារីត្រូវបានបង្កើតឡើងដោយឡែក និងអន្តរវិស័យអាទិភាពរបស់ជាតិដែលឧទាហរណ៍គួរឱ្យកត់សម្គាល់អាចរកឃើញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១, ២, ៣ និងទី៤ សម្រាប់កំណើនការងារសមធម៌ និងប្រសិទ្ធភាពដែលជាកម្មវិធីនយោបាយរបស់រដ្ឋាភិបាល។ ថ្មីៗនេះ ក្រសួងកិច្ចការនារីបានដើរតួនាទីដឹកនាំក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ ដោយផ្អែកលើមេរៀនដែលទទួលបាន និងបទពិសោធក្នុងការអនុវត្តគោលនយោបាយជាតិ កម្មវិធី និងយុទ្ធសាស្ត្រសំខាន់ៗដោយប្រើប្រាស់លទ្ធផលនៃការប៉ាន់ប្រមាណតម្លៃយេនឌ័រកម្ពុជា (Cambodia Gender Assessment) ឆ្នាំ២០១៩ ។ ប៉ុន្តែគោលនយោបាយដែលបានព្រាងមិនត្រូវបានលើកឡើងជាក់ច្បាស់ក្នុងការជំរុញការចូលរួមនយោបាយរបស់ស្ត្រីទេ។

គោលនយោបាយជាតិ ស្តីពី សមភាពយេនឌ័រនេះផ្តល់នូវក្របខ័ណ្ឌគោលនយោបាយរយៈពេលវែង និងលើកកម្ពស់គោលការណ៍សមភាពយេនឌ័រនៅក្នុងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (National Strategic Development Plan) និងផែនការយុទ្ធសាស្ត្រតាមវិស័យ ដើម្បីសម្រេចបានសមភាពយេនឌ័រស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងគោលបំណង «មិនទុកនរណាម្នាក់ចោល» និងគោលការណ៍របស់ស៊ី-ដ នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍ។ បន្ថែមលើនេះទៀត ក្រសួងកិច្ចការនារីបានបន្តពង្រឹងការអនុវត្តផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់គ្រប់ទម្រង់នៃអំពើហឹង្សាប្រឆាំងនឹងស្ត្រី និងកុមារី ចាប់ពី ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២៣ និងដើម្បីស្តារឡើងវិញនូវសីលធម៌សង្គម ដោយយកចិត្តទុកដាក់លើការអប់រំសង្គមសម្រាប់ការផ្លាស់ប្តូរផ្នត់គំនិតដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី។ យោងតាមរបាយការណ៍របស់ខុមហ្វ្រែល[9] ឥរិយាបទរើសអើងចំពោះស្ត្រីនៅក្នុង

[9] https://comfrel.org/political-gender-watch-2019-comfrel-official

ក្រុមប្រឹក្សាឃុំ សង្កាត់បានថយចុះគួរឱ្យកត់សម្គាល់ ដោយមានការគាំទ្រ និងលើកកម្ពស់ស្ត្រីពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបុរស និងមេភូមិ។

មានការផ្លាស់ប្តូរឥរិយាបថផ្តល់តម្លៃដល់ស្ត្រី យល់អំពីយេនឌ័រ ការគោរពសិទ្ធិស្ត្រី និងមានកិច្ចសហប្រតិបត្តិការល្អជាមួយស្ត្រី។ ទោះយ៉ាងណា ការរើសអើងប្រឆាំងនឹងស្ត្រីនៅក្នុងនយោបាយ ជាពិសេសស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តកើតមាន។ លើសពីនេះ អ្នកនយោបាយស្ត្រីខ្លះប្រើសិទ្ធិរបស់ពួកគេដើម្បីចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ ដូចជាការប្រជុំ និងការពិភាក្សានយោបាយនៅកម្ពុជាបានប្រឈមនឹងការចោទប្រកាន់ពីតុលាការ ការរើសអើង ការឃាយឃី ការបំភិតបំភ័យ និងការរំលោភបំពានពីសំណាក់អាជ្ញាធរ។ សកម្មភាពរបស់ពួកគេក៏ត្រូវបានរំខានដោយអាជ្ញាធរមូលដ្ឋានផងដែរ។ ជាក់ស្តែង អ្នកនយោបាយ សកម្មជននយោបាយ និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់នៃអតីតគណបក្សសង្គ្រោះជាតិត្រូវទទួលរងនូវការចោទប្រកាន់ពីតុលាការ ការរើសអើង ការឃាយឃីការបំភិតបំភ័យ និងការរឹតត្បិតពីសំណាក់អាជ្ញាធរ ចាប់តាំងពីគណបក្សនេះត្រូវបានរំលាយដោយតុលាការកំពូលក្នុងឆ្នាំ២០១៧។ លើសពីនេះទៀត និយាមវប្បធម៌សង្គមមួយចំនួន កង្វះការអប់រំដែលមានគុណភាពល្អសម្រាប់ស្ត្រី និងក្មេងស្រី កង្វះនៃការរើសអើងជាវិជ្ជមាននៅក្នុងកម្មវិធីនយោបាយ កង្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងនយោបាយសម្រាប់ស្ត្រីក្នុងវិស័យនយោបាយក៏ដូចជាឧបសគ្គស្ថាប័ន គឺជាកត្តារួមចំណែកដល់អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ និងរារាំងពួកគេមិនឱ្យក្លាយជាអ្នកដឹកនាំនយោបាយ។ ឧទាហរណ៍នៅចន្លោះដើមឆ្នាំ និងពាក់កណ្តាល ឆ្នាំ២០១៩ អ្នកនយោបាយស្ត្រីដែលបានប្រើសិទ្ធិនយោបាយ និងសិទ្ធិស្ត្រីរបស់ពួកគេ ដើម្បីចូលរួមក្នុងដំណើរការប្រជាធិបតេយ្យនៅកម្ពុជាត្រូវបានប្រឈមការចោទប្រកាន់តាមផ្លូវតុលាការ រួមទាំង ការរើសអើង ការឃាយឃី ការគំរាមកំហែង និងការរឹតត្បិតពីសំណាក់អាជ្ញាធរ សូម្បីតែការជួបប្រជុំគ្នា និងការពិភាក្សាគ្នាអំពីរឿងនយោបាយរបស់ស្ត្រីក៏ត្រូវបានរំខានផងដែរ ដូចជា សារព្រមានរបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែន អតីតស្ត្រីមេឃុំអូរចារ ខេត្តបាត់ដំបង ត្រូវបានតុលាការកោះហៅទៅបំភ្លឺជាបន្តបន្ទាប់ ការជួបជុំរួមគ្នារបស់អតីតសមាជិក និងមន្ត្រីគណបក្សសង្គ្រោះជាតិត្រូវបានរំខានដោយអាជ្ញាធរ ហើយក្រុមស្ត្រីដែលជាប់ឆ្នោត៦នាក់ជាមេឃុំ ជាសមាជិកក្រុមប្រឹក្សាខេត្ត និងស្រុកនៃអតីតគណបក្សសង្គ្រោះជាតិ នៅខេត្តកំពង់ស្ពឺត្រូវបង្ខំរត់គេចខ្លួនដើម្បីសុវត្ថិភាព ចៀសពីការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធររបបក្រុងភ្នំពេញផងដែរ។

សកម្មភាពរបស់រដ្ឋាភិបាល និងទង្វើរបស់អាជ្ញាធរ ជាការប្រព្រឹត្តិផ្ទុយនឹងអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (ស៊ី-ដ) មាត្រា៣ចែងថា « *ក្នុងគ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស ។* » និងមាត្រា៧ បានចែងថា « *រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងជីវភាព*

*នយោបាយ និងសាធារណៈរបស់ប្រទេស។...»* ។ សកម្មភាពខាងលើក៏ជារំលោភបំពានលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានការពារសិទ្ធិ សេរីភាពបញ្ចេញមតិ និងការជួបប្រជុំដែលមានចែងក្នុងមាត្រា៤១៖ « *ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។...»* និងបានរំលោភបំពានយ៉ាងខ្លាំងលើកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩ កថាខណ្ឌ២ ចែងថា « *ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។...»* ។

កម្ពុជានៅបន្តរក្សាបញ្ហាវិសមភាពនៃភាពជាតំណាងរវាងស្ត្រី និងបុរសក្នុងកិច្ចការសាធារណៈ និងជីវិតនយោបាយ - រួមទាំងនៅក្នុងគណបក្សនយោបាយ ជាផ្នែកមួយនៃដំណើរការបង្កើតច្បាប់ ជាបេក្ខជនឈរឈ្មោះ និងតំណាងជាប់ឆ្នោត។ ផ្នែកចម្បងនៃបញ្ហានេះ គឺដោយសារខ្វះនូវគោលនយោបាយជាក់លាក់ជាលាយលក្ខណ៍អក្សរដែលជាវិធានការពិសេស និងខ្វះនូវច្បាប់ឆ្លើយតបនឹងយេនឌ័រ ជាពិសេសច្បាប់បោះឆ្នោតដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រី និងបុរសចូលរួមស្មើគ្នាលើតួនាទីសម្រេចចិត្តក្នុងវិស័យសាធារណៈនិងវិស័យនយោបាយស្របតាមអនុសញ្ញា ស៊ី-ដ ដែលកម្ពុជាបានផ្តល់សច្ចាប័ន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ដែលប្រទេសកម្ពុជាបានទទួលយក។ អត្ថិភាពនៃការរើសអើង ខ្វះការលើកទឹកចិត្ត និងឆន្ទៈនយោបាយរបស់គណបក្សនយោបាយដែលមានសក្តានុពលខ្ពស់ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រី ។ លើសពីនេះទៅទៀត អ្នកដឹកនាំជាបុរសនៅតែរក្សាអំណាចនយោបាយរបស់ពួកគេ ហើយមិនចង់ចុះចេញពីតំណែង។ ចំនួនស្ត្រីជាប់ឆ្នោតតិចសម្រាប់ការបោះឆ្នោត ទាំងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ ។ អ្នកតំណាងរាស្ត្រស្ត្រីជាប់ឆ្នោតមានចំនួនតែ ២០% និងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មានតែ ២០% នៃក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៤ ឆ្នាំ ២០១៧ រួមទាំង ចំនួនស្ត្រីទាបនៅថ្នាក់សម្រេចចិត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ខណៈដែល តំណាងបុរសមានចំនួនច្រើនលើសលប់។

យោងតាមរបាយការណ៍ដែលចេញដោយអគ្គលេខាធិការដ្ឋានរដ្ឋសភានៅដើម ឆ្នាំ២០២០ ខាងក្រោមនេះ គឺជាទិដ្ឋភាព និងតួលេខមួយចំនួនអំពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងនយោបាយនៅកម្ពុជា៖[10]

- ក្នុងរយៈពេលពីរទសវត្សរ៍ អ្នកតំណាងស្ត្រីនៅរដ្ឋសភាបានកើនឡើងគួរឱ្យកត់សម្គាល់ពី ៦% ដល់ ២១% ខណៈសមាជិកព្រឹទ្ធសភាស្ត្រីនៅទ្រឹង ១៦%
- ចៅក្រមជាស្ត្រីមានត្រឹមតែ ១៥%នៃចៅក្រមទាំងអស់ ។ ១៤% ជាព្រះរាជអាជ្ញា មេធាវី ២២% និងសាការីសាធារណៈ ១២% (គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២០) ។
- ស្ត្រីមានប្រហែល ១៦%នៃតំណែងជាន់ខ្ពស់របស់រដ្ឋាភិបាល ចាប់ពីអនុរដ្ឋលេខាធិការ រហូតដល់

[10] http://nac.org.kh/Images/Women%20in%20leadership-Eng-Final.pdf?fbclid=IwAR3-zc5x1fNII7fnSKpCoOm4VqSX8v5rVoAXob7WEgdEQbBxoZTxKYv6AHA

ឧបនាយករដ្ឋមន្ត្រី (គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២០)។

- ស្ត្រីមានតំណែងអភិបាលខេត្តតែ ៤%ប៉ុណ្ណោះ
- ស្ត្រីបម្រើជាមន្ត្រីជាន់ខ្ពស់គឺទាបជាងបុរសទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ ស្ត្រីភាគច្រើនបានបម្រើការជាអនុប្រធានការិយាល័យ។
- ការចូលរួមរបស់ស្ត្រីនៅក្នុងប្រព័ន្ធតុលាការមានកម្រិតទាបក្នុងរយៈពេល ៧ឆ្នាំនៃការបម្រើ (ឆ្នាំ២០១៣-ឆ្នាំ២០២០)។
- អំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅតែជាបញ្ហាដែលរីករាលដាលនៅក្នុងប្រទេស។ ស្ត្រីដែលមានអាយុចន្លោះពី ១៥ឆ្នាំ ទៅ ៦៤ឆ្នាំនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថា ពួកគេ ៣០%បានជួបប្រទះនូវអំពើហឹង្សាលើរាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងសេដ្ឋកិច្ច។

## 4.2 លទ្ធផលពីការស្ទង់មតិ

| | |
|---|---|
| **1) សារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ** | <br><br>***សំណួរទី៥៖ តើការចូលរួមនយោបាយរបស់ស្ត្រីនៅកម្ពុជាមានសារៈសំខាន់កម្រិតណា? (១ មិនសំខាន់> ៥ សំខាន់បំផុត)***<br>ការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយ គឺសំខាន់ណាស់ ពីព្រោះពួកគេទាំងជាអ្នកដឹកនាំ និងជាអ្នកគាំទ្រអ្នកនយោបាយបុរស។ អ្នកឆ្លើយសំណួរ ៨០%បានយល់ស្របថា ការចូលរួមនយោបាយរបស់ស្ត្រីគឺមានសារៈសំខាន់ណាស់នៅកម្ពុជា។ សកម្មជននយោបាយស្ត្រីម្នាក់បាននិយាយថា *«ស្ត្រីកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងនយោបាយ ចូលរួមក្នុងការដោះស្រាយបញ្ហារបស់ស្ត្រី និងកុមារ ការអភិវឌ្ឍសង្គម និងជាផ្នែកមួយនៃដំណើរការបង្កើតគោលនយោបាយ/ច្បាប់។ ស្ត្រីមិនត្រឹមតែជាមេដឹកនាំនយោបាយ និងជាតំណាងជាប់* |

| | |
|---|---|
| | *ឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកគាំទ្រដែលមិនរួញរាចំពោះអ្នកនយោបាយបុរសក៏ដូចជាគណបក្សផងដែរ ។»* |
| 2) កម្រិតនៃការចូលរួមរបស់ស្ត្រីក្នុងនយោបាយ | <br>***សំណួរទី ៦៖ តើអ្នកអាចវាយតម្លៃកម្រិតនៃការចូលរួមនយោបាយរបស់ស្ត្រីនៅកម្ពុជាបានទេ ? ( ១ ទាបបំផុត >៥ ខ្ពស់បំផុត)***<br><br>ទោះបីជាចំនួនអ្នកដឹកនាំនយោបាយស្ត្រីនៅកម្រិតទាបនៅកម្ពុជាក៏ដោយ ក៏ស្ត្រីកម្ពុជាទូទៅបានចូលរួមយ៉ាងសកម្មនៅក្នុងនយោបាយ។ ៩១%នៃអ្នកចូលរួមការស្ទង់មតិបានបង្ហាញថា ស្ត្រីកំពុងចូលរួមយ៉ាងខ្លាំងនៅក្នុងនយោបាយក្នុងនាមជាអ្នកគាំទ្រនយោបាយ ជាសកម្មជននយោបាយ ជាអ្នកនយោបាយ និងជាអ្នកបោះឆ្នោត។ អតីតសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីបានមានប្រសាសន៍ថា *«ទោះបីជាវប្បធម៌នយោបាយនៅកម្ពុជាមិនសូវអំណោយផលសម្រាប់ស្ត្រីក៏ដោយ ពួកគេនៅតែចូលរួមក្នុងសកម្មភាពផ្សេងៗ ជាពិសេសការបោះឆ្នោត»។* |
| 3) ការយល់ដឹងអំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ | <br>***សំណួរទី៧៖ តើអ្នកមានដឹងអំពីទម្រង់នានានៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងនយោបាយទេ ?*** |

មិនទាន់មានការយល់ដឹងឱ្យបានទូលំទូលាយអំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយនៅក្នុងប្រទេសកម្ពុជានៅឡើយ ពីព្រោះ ២៣,៦% នៃអ្នកឆ្លើយតបថា មិនប្រាកដអំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ។ អ្នកចូលរួមការសិក្សា ៧៤.៥% បានយល់ច្បាស់អំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ។ ប៉ុន្តែ ១,៨% នៃអ្នកចូលរួមការសិក្សា មិនដឹងថាតើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយជាអ្វីឡើយ។ សកម្មជននយោបាយម្នាក់នៅខេត្តបាត់ដំបងបាននិយាយថា *«ខ្ញុំសង្កេតឃើញថា មិនមានមនុស្សច្រើនទេរួមទាំងសហសេវិកបុរសមួយចំនួននៅក្នុងគណបក្សតែមួយនិងអាជ្ញាធរមូលដ្ឋានផងដែរ មិនបានដឹងច្បាស់អំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ ហើយវាបានក្លាយជាវប្បធម៌អាក្រក់នៅក្នុងប្រទេសកម្ពុជា»។*

**4) បទពិសោធអំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ**




*សំណួរទី១២៖ តើអ្នក (ស្ត្រី) ធ្លាប់មានបទពិសោធពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយឬទេ?*

លទ្ធផលនៃការស្ទង់មតិនេះបានបង្ហាញថា ៧១,៧% នៃអ្នកឆ្លើយសំណួរបានជួបប្រទះនឹងអំពើហឹង្សាលើស្ត្រីដែលបានឆ្លុះបញ្ចាំងឱ្យឃើញថា អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយនៅកម្ពុជាគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ។ ហើយ ២២,៦% នៃអ្នកចូលរួមមិនដែលជួបប្រទះទេ។ ទោះបីយ៉ាងណាក៏ដោយ ៥,៧% នៃអ្នកចូលរួមបានឆ្លើយថាមិនប្រាកដ។ ស្រដៀងគ្នានេះដែរ ស្ត្រីម្នាក់នៅក្នុងក្រុមពិភាក្សាបានថ្លែងថា៖ *«សកម្មជននយោបាយស្ត្រី និងអ្នកនយោបាយស្ត្រីភាគច្រើន*

*មកពីគណបក្សប្រឆាំងបានជួបប្រទះនឹងអំពើហឹង្សាលើស្ត្រី ខណៈដែលស្ត្រីនៅក្នុងគណបក្សផ្សេងៗ និងគណបក្សកាន់អំណាចពិតជាមិនមែនជាគោលដៅនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយនៅសព្វថ្ងៃនេះ។»*

5) សញ្ញាណ និងទម្រង់នៃអំពីហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ




*សំណួរទី១០៖ ចូរធ្វើចំណាត់ថ្នាក់ពី 1-7 ពីញឹកញាប់បំផុតនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងនយោបាយ ទៅតិចតួចបំផុត?*

*ទម្រង់ទូទៅបំផុតនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងនយោបាយ គឺការគំរាមកំហែង និងអំពើហឹង្សាផ្លូវចិត្ត។ ៨១,៨% នៃអ្នកចូលរួមការសិក្សា បានប្រឈមនឹងការគំរាមកំហែង និង៧០,៩% ប្រឈមនឹងអំពើហឹង្សាផ្លូវចិត្ត។ អតីតសកម្មជនគណបក្សប្រឆាំងម្នាក់បាននិយាយថា «វាពិបាកសម្រាប់ខ្ញុំក្នុងការរស់នៅបានសុខសព្វថ្ងៃនេះ ពីព្រោះខ្ញុំបានប្រឈមមុខនឹងអំពើហឹង្សាខាងផ្លូវចិត្ត និងការគំរាមកំហែងច្រើនពេក។ ជនល្មើសមិនដែលបានផ្តល់ឱ្យខ្ញុំនូវការសម្រាកដើម្បីរស់នៅក្នុងជីវិតសាមញ្ញទេ ទោះបីជាគណបក្សរបស់ខ្ញុំត្រូវបានរំលាយយូរមកហើយ។»*

ទម្រង់ធ្ងន់ធ្ងរមួយនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ គឺការរំលោភបំពានលើរាងកាយ និងការយាយីផ្លូវភេទ។ លទ្ធផលនៃការសិក្សាបានបង្ហាញថា ស្ត្រីអ្នកចូលរួម ចំនួន ៣៤.៥% បានទទួលរងនូវការរំលោភបំពានលើរាងកាយ ហើយ ៩,១% ទទួលរងការយាយីផ្លូវភេទ។ អ្នកជំនាញផ្នែកយេនឌ័របានថ្លែងថា «វាមិនអាចទទួលយកបានទេចំពោះទង្វើគ្មានសីលធម៌ទាំងនេះ ហើយវាផ្ទុយនឹងអនុសញ្ញា

<table>
<tr>
<td></td>
<td>អន្តរជាតិ « ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី (ស៊ី-ដរ/CEDAW)ដែលកម្ពុជាបានផ្តល់សច្ចាប័ន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ដែលកម្ពុជាប្តេជ្ញាចិត្តបានទទួលយកដើម្បីការពារស្ត្រីពីការរើសអើង និងអំពើហឹង្សា ក៏ដូចជាផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងកុមារី។»</td>
</tr>
<tr>
<td>6) មូលហេតុដែលនាំឱ្យមានអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ</td>
<td>

<br>
សំណួរទី១១៖ ហេតុអ្វីបានជាអ្នកគិតថាគេប្រព្រឹត្តិអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងនយោបាយ?
<br><br>
មូលហេតុសំខាន់ពីរនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយគឺ៖ ១) នយោបាយមិនមែនជារឿងផ្ទាល់ខ្លួនទេ ប៉ុន្តែជាការប្រកួតប្រជែងគណបក្សនយោបាយដើម្បីអំណាច និង ២) បុរសខ្លាចស្ត្រីទទួលបានអំណាចច្រើនជាងខ្លួន។ ៤៧,៣% នៃអ្នកចូលរួមបានបង្ហាញថា អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយមិនមែនជារឿងផ្ទាល់ខ្លួនទេ ប៉ុន្តែជាការប្រកួតប្រជែងរបស់គណបក្សនយោបាយដើម្បីអំណាច ដូច្នេះពួកគេចង់បញ្ឈប់ស្ត្រីមិនឱ្យចូលរួមក្នុងឆាកនយោបាយជាមួយនឹងហេតុផលផ្សេងទៀត ដូចជាស្ត្រីមិនអាចក្លាយជាអ្នកនយោបាយល្អ និងបុរសខ្លាំងជាងស្ត្រី។ សកម្មជនសិទ្ធិស្ត្រីម្នាក់បានអះអាងថា «ធម្មជាតិ និងដំណើរការនៃនយោបាយនៅកម្ពុជា គឺគ្រប់គ្រង ឬគ្រប់សង្កត់ដោយបុរស។ ដូច្នេះសម្រាប់ហេតុផលខ្លះ បុរសមិនចង់បាត់បង់អំណាចរបស់ពួកគេ (មិនចង់ចុះចេញពីតំណែង) ឱ្យទៅស្ត្រី ឬពួកគេខ្លាចស្ត្រីមានអំណាច។»</td>
</tr>
</table>

<table>
<tr>
<td>7) ជនល្មើសប្រព្រឹត្តិអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ</td>
<td>


<br>
សំណួរទី ៩៖ តើនរណាជាជនល្មើសប្រព្រឹត្តិអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងឆាកនយោបាយ និងគណបក្សនយោបាយ?
<br>
ជនល្មើសសំខាន់ប្រព្រឹត្តិអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ គឺសមាជិកគណបក្សនយោបាយដែលជាគូប្រជែង សមាជិកក្នុងគណបក្សនយោបាយតែមួយ និងប៉ូលីស អាជ្ញាធរមូលដ្ឋាន។ ៧៩,៦% នៃអ្នកចូលរួមការសិក្សាបានឆ្លើយថា ជនល្មើសនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ គឺសមាជិកគណបក្សនយោបាយដែលជាគូប្រជែង។ សកម្មជននយោបាយស្ត្រីម្នាក់បានថ្លែងថា «ដោយសារជម្លោះនយោបាយនៅកម្ពុជា អ្នកចូលរួមប្រកួតប្រជែងមកពីគណបក្សនយោបាយផ្សេងទៀត ជាពិសេសគណបក្សកាន់អំណាចមិនចាត់ទុកយើងជាគូប្រជែងទេ ប៉ុន្តែចាត់ទុកជាសត្រូវដែលជាហេតុធ្វើឱ្យពួកគេខ្លះប្រកាន់យកនយោបាយជារឿងផ្ទាល់ខ្លួន។»
</td>
</tr>
<tr>
<td>8) ការរាយការណ៍អំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ</td>
<td>


<br>
សំណួរទី១៣៖ តើអ្នកបានរាយការណ៍អំពីអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយឬទេ?
</td>
</tr>
</table>

<table>
<tr><td></td><td>អ្នកចូលរួមការសិក្សា ៥២.៧% បញ្ជាក់ថា បានរាយការណ៍អំពីអំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ។ ៣៤.៥% នៃអ្នកចូលរួមការសិក្សាមិនបានរាយការណ៍ឡើយ ហើយ ១២,៧% នៃអ្នកចូលរួមការសិក្សាបានបដិសេធមិនផ្តល់ចម្លើយ។ អ្នកសិក្សាស្រាវជ្រាវម្នាក់បាននិយាយថា «អ្នកនយោបាយ ឬសកម្មជនស្ត្រីមួយចំនួនមិនហ៊ានរាយការណ៍អំពីអំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយដោយសារពួកគេខ្លាចថ្នាក់លើរបស់ខ្លួន ការបំផ្លាញកេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់ពួកគេនៅពេលដែលឧប្បត្តិហេតុត្រូវបានគេដឹងជាសាធារណៈ។»</td></tr>
<tr><td>9) ការទទួលស្គាល់អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ</td><td>

<br>
សំណួរទី១៦៖ តើមានការទទួលស្គាល់អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយនៅក្នុងគណបក្សដែរឬទេ?
<br>
អ្នកចូលរួមការសិក្សា ២៤.១% បានបញ្ជាក់ថា មានការទទួលស្គាល់អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ។ ទោះយ៉ាងណា ៤២.៦% នៃពួកគេបានឆ្លើយតបថា គ្មានការទទួលស្គាល់អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយឡើយ ហើយ ៣៣,៣% នៃអ្នកចូលរួមការសិក្សាមិនបានដឹងអំពីការទទួលស្គាល់ណាមួយឡើយ។ សកម្មជនសិទ្ធិស្ត្រីម្នាក់បាននិយាយថា «ដោយសារអំពើហិង្សានយោបាយគឺជាផ្នែកមួយនៃវប្បធម៌នយោបាយនៅក្នុងប្រទេសកម្ពុជា មនុស្សជាច្រើនមិនបានទទួលស្គាល់ថាវាជាបញ្ហានោះទេ ប៉ុន្តែវាជាបញ្ហាប្រឈមដែលមានជាក់ស្តែងនៅក្នុងការរស់នៅ ហើយខ្ញុំគិតថាទាំងមេដឹកនាំនយោបាយ</td></tr>
</table>

<table>
<tr><td></td><td>និងអ្នកនយោបាយត្រូវការផ្លាស់ប្តូរឥរិយាបថរបស់ពួកគេចំពោះបញ្ហានេះ។»</td></tr>
<tr><td>10)	ការទទួលខុសត្រូវដើម្បីបង្ការអំពើហឹង្សាប្រឆាំងនឹងស្ត្រី</td><td>



សំណួរទី១៥៖ តើមានអ្នកទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងគណបក្សនយោបាយឬទេ?

អ្នកចូលរួមការស្រាវជ្រាវចំនួន ៤១.៨% បានបញ្ជាក់ថា មានមន្ត្រីទទួលបន្ទុកបញ្ហាអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយ ឬការរើសអើងនៅក្នុងគណបក្សនយោបាយ។ ទោះយ៉ាងណា ៣៨,២% នៃអ្នកចូលរួមការសិក្សាបានបង្ហាញថា មិនមានមន្ត្រីដាក់លាក់ទទួលបន្ទុកចំពោះបញ្ហាអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយនៅក្នុងគណបក្សរបស់ពួកគេឡើយ  ហើយ ២០% នៃពួកគេមិនបានដឹងអំពីយន្តការរបស់គណបក្សនយោបាយក្នុងការដោះស្រាយបញ្ហាអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយដែរ។ សកម្មជនសិទ្ធិស្ត្រីម្នាក់បាននិយាយថា «តាមរយៈការងាររបស់ខ្ញុំជាមួយគណបក្សនយោបាយ ខ្ញុំបានរកឃើញថា គណបក្សភាគច្រើនមិនទាន់មានគោលនយោបាយសមភាពយេនឌ័រ និងក្រមសីលធម៌ប្រឆាំងអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយនៅឡើយទេ។ ទោះបីជាគណបក្សខ្លះមាន ក៏ប្រសិទ្ធភាពនៃការងាររបស់ពួកគេនៅមានកម្រិតដែលត្រូវការការយកចិត្តទុកដាក់និងការប្តេជ្ញាចិត្តខ្ពស់ ជាពិសេសឆន្ទៈនយោបាយនិងគណនេយ្យភាពរបស់អ្នកដឹកនាំ។»
</td></tr>
</table>

<table>
<tr>
<td>11) ផលប៉ះពាល់អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ</td>
<td>




***សំណួរទី១៨៖ តើអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយមានផលប៉ះពាល់អ្វីខ្លះ?***

អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងនយោបាយមិនបានលើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងនយោបាយ។ ពួកគេកាន់តែមានអារម្មណ៍ឯកោ។ ហេតុដូច្នេះការចូលរួមនយោបាយរបស់ពួកគេ ជាពិសេសក្នុងការឈរឈ្មោះបោះឆ្នោត និងការបោះឆ្នោតត្រូវបានកាត់បន្ថយ និងតូចចង្អៀត។ លទ្ធផលនៃបទសម្ភាសបានបង្ហាញថា ស្ត្រីមួយចំនួនមិនហ៊ានបង្ហាញ ឬរាយការណ៍អំពីអំពើហឹង្សា ឬការរើសអើងប្រឆាំងនឹងពួកគេនៅក្នុងគណបក្ស ពីព្រោះពួកគេខ្លាចថា ការបង្ហាញនេះអាចជះឥទ្ធិពលអវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់ស្ត្រី គណបក្សខ្លួនឯង ភាពជឿជាក់ និងកិត្តិយសនៃគណបក្ស។ ហេតុនេះហើយ ស្ត្រីអាចត្រូវបានរាំងមិនឱ្យចូលរួម ឬបន្តការចូលរួមរបស់ពួកគេជាមួយគណបក្ស ខ្វះឱកាសក្នុងការចូលរួមដោយស្មើភាពនៅក្នុងនយោបាយ ហើយការអនុវត្តសិទ្ធិនយោបាយរបស់ពួកគេមិនស្របតាមអនុសញ្ញាស៊ី-ដ។

</td>
</tr>
<tr>
<td>12) បញ្ហាប្រឈមទាក់ទងនឹងការលើកកម្ពស់ស្ត្រីនៅក្នុងគណបក្សនយោបាយ និងនយោបាយ</td>
<td>




</td>
</tr>
</table>

| | |
|---|---|
| | *សំណួរទី២០៖ តើស្ត្រីប្រឈមនឹងបញ្ហាអ្វីខ្លះទាក់ទងនឹងការតម្លើងឋានៈនៅក្នុងគណបក្សនយោបាយ? (១ មិនសូវប្រឈម, ៥ ប្រឈមខ្លាំងបំផុត)*<br><br>ស្ត្រីខ្មែរនៅតែប្រឈមមុខនឹងបញ្ហាធំៗជាច្រើនក្នុងការទទួលបានមុខតំណែងជាអ្នកដឹកនាំនៅក្នុងគណបក្សនយោបាយ។ អ្នកចូលរួមការសិក្សាជាង ៩២,៧% បានឆ្លើយថា ស្ត្រីមានការប្រឈមយ៉ាងខ្លាំងដើម្បីក្លាយជាមេដឹកនាំនយោបាយនៅក្នុងគណបក្សរបស់ពួកគេ។ ២៧.៣% នៃអ្នកចូលរួមការសិក្សាបានឆ្លើយថា ស្ត្រីមានការប្រឈមខ្លាំងបំផុតក្នុងការក្លាយជាមេដឹកនាំនយោបាយនៅក្នុងគណបក្សនយោបាយ។ អ្នកឯកទេសផ្នែកសិទ្ធិស្ត្រីម្នាក់បានអះអាងថា *«អ្នកនយោបាយ ឬសកម្មជនស្ត្រីជាច្រើនពូកែ ប៉ុន្តែសហសេវិកជាបុរសរបស់ពួកគេ ជាពិសេសបុរសវ័យចំណាស់មិនផ្តល់ឱកាសឱ្យពួកគេកាន់កាប់តំណែងជាអ្នកដឹកនាំនោះទេ។ ខ្ញុំគិតថាមានគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្សហើយការអនុវត្តល្អនឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ស្ត្រីដើម្បីទាមទារសិទ្ធិរបស់ពួកគេ និងចាប់យកឱកាសស្មើគ្នាជាបេក្ខជន និងជាប់ឆ្នោត។»* |
| **13) ការគាំទ្រស្ត្រីដើម្បីជំនះអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ** | <br><br><br>*សំណួរទី២៣៖ តើស្ត្រីទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីជំនះឧបសគ្គ និងអំពើហឹង្សាប្រឆាំងនឹងពួកគេដែរទេ? (១ មិនគ្រប់គ្រាន់ទាល់តែសោះ, ៥ គ្រប់គ្រាន់បំផុត)*<br><br>អ្នកចូលរួមការសិក្សា ៨៦% បានឆ្លើយថា ស្ត្រីខ្មែរមិនទាន់ទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីជំនះឧបសគ្គ និងអំពើហឹង្សាប្រឆាំងនឹងពួកគេក្នុងឆាកនយោបាយនៅឡើយទេ។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់បាន |

និយាយថា *«ការគាំទ្រសម្រាប់អ្នកនយោបាយស្ត្រី ឬសកម្មជនស្ត្រីមានតិចណាស់។ ប៉ុន្តែស្ត្រីប្រឈមមុខនឹងបញ្ហាច្រើនជាងអ្នកនយោបាយបុរស ពីព្រោះអ្នកនយោបាយស្ត្រី ឬសកម្មជនស្ត្រីចាំបាច់ត្រូវជំនះឧបសគ្គជាច្រើនដើម្បីចូលរួមពេញលេញនៅក្នុងនយោបាយ ជាពិសេស តម្រូវការនៃតួនាទីរបស់ពួកគេក្នុងនាមជាម្ដាយ ភរិយា ឬកូនប្រសារនៅក្នុងគ្រួសារក៏កំពុងតែទាញពួកគេទៅក្រោយផងដែរ។»*




*សំណួរទី២៤៖ តើស្ថាប័នសាធារណៈ (ស្ថាប័នអប់រំ ធនាគារគំនិត ជាដើម) និងអង្គការក្រៅរដ្ឋាភិបាលមានការគាំទ្រកម្រិតណាដើម្បីលើកស្ទួយដល់ការចូលរួមដោយស្មើភាពរបស់ស្ត្រីនៅក្នុងនយោបាយ? (១ គាំទ្រតិចបំផុត, ៥ គាំទ្រច្រើនបំផុត)*

មានការគាំទ្រតិចតួចពីស្ថាប័នអប់រំ ធនាគារគំនិត អង្គការមិនមែនរដ្ឋាភិបាលជាដើមដើម្បីឱ្យស្ត្រីអាចយកឈ្នះលើអំពើហឹង្សាប្រឆាំងនឹងពួកគេនៅក្នុងវិស័យនយោបាយ។ កម្រិតនៃការគាំទ្រដែលមានសម្រាប់ស្ត្រីគឺស្ថិតនៅក្រោមមធ្យម។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់បានថ្លែងថា *«ខ្ញុំមានអំណរគុណចំពោះការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពដើម្បីជួយស្ត្រីក្នុងនយោបាយ ដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ ខ្ញុំយល់ឃើញថា វាមានប្រយោជន៍ណាស់។ ទោះជាយ៉ាងណាក៏ដោយ ឱកាសដើម្បីរៀនគឺយូរៗទើបមានម្ដង។ ខ្ញុំដឹងថា គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលពឹងផ្អែកលើថវិកាពីបរទេស។ ដូច្នេះវាពិបាកក្នុងការស្នើសុំការបណ្ដុះបណ្ដាលបន្ថែមទៀត។ ដោយសារនយោបាយមិនត្រូវបានបង្រៀននិងពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងសាលារៀន វេទិកាអង្គការមិនមែនរដ្ឋាភិបាលគឺជា*

<table>
<tr>
<td></td>
<td>ប្រកតែមួយគត់ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយ និងតួនាទីរបស់ពួកគេជាមេដឹកនាំនយោបាយ។»</td>
</tr>
<tr>
<td>14 ) តម្រូវការសម្រាប់គណបក្សនយោបាយអនុម័តគោលនយោបាយសមភាពយេនឌ័រ</td>
<td>


<br>
សំណួរទី២៦៖ គណបក្សនយោបាយគួរតែមានគោលនយោបាយសមភាពយេនឌ័រដើម្បីលើកកម្ពស់ការចូលរួមស្មើគ្នារបស់ស្ត្រីដែរឬទេ ?
<br>
ការស្ទង់មតិបានបង្ហាញថា ៩៨,២% នៃអ្នកចូលរួមបានឆ្លើយថា គណបក្សនយោបាយគួរតែមានគោលនយោបាយសមភាពយេនឌ័រ ហើយការអនុវត្តវាឱ្យបានល្អដើម្បីលើកកម្ពស់ការចូលរួមស្មើភាពគ្នារបស់ស្ត្រីនៅក្នុងនយោបាយ។ គណបក្សនីមួយៗគួរតែប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំ/ក្រមប្រព្រឹត្តិផ្ទៃក្នុងប្រឆាំងនឹងអាកប្បកិរិយាហឹង្សាក្នុងចំណោមសមាជិកបក្ស។ អ្នកចូលរួមការសម្ភាសម្នាក់បានថ្លែងថា «តាមបច្ចេកទេស គណបក្សនយោបាយចាំបាច់ត្រូវអនុម័តគោលនយោបាយសមភាពយេនឌ័រ ពីព្រោះវានឹងការពារ និងផ្តល់ឱកាសកាន់តែច្រើនដល់អ្នកនយោបាយស្ត្រី។ ទោះជាយ៉ាងណាក៏ដោយ តម្រូវការមិនខ្លាំងគ្រប់គ្រាន់ ដែលទាមទារឱ្យមានការបញ្ចុះបញ្ចូលនិងការតស៊ូមតិរួមបញ្ចូលគ្នាប្រកបដោយប្រសិទ្ធភាពសម្រាប់ការអនុម័តគោលនយោបាយនេះ។»
</td>
</tr>
</table>

<table>
<tr>
<td>15) ធន្ទៈក្នុងការបន្តចូលរួមនយោបាយ</td>
<td>



សំណួរទី២៧៖ ដោយមើលឃើញពីស្ថានភាពនយោបាយមានការផ្លាស់ប្តូរយ៉ាងខ្លាំង ជាពិសេសក្នុងអំឡុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ រួមទាំងការរួមតូចនៃលំហរប្រជាធិប តេយ្យសម្រាប់ពលរដ្ឋ ការបិទប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ការធ្លាក់ចុះនៃការគោរពសិទ្ធិមនុស្ស និងការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិល និងការរំលាយគណបក្សសង្គ្រោះជាតិ។ មានការបំភិតបំភ័យ និងការរឹតត្បិតលើអ្នកនយោបាយស្ត្រី និងផលប៉ះពាល់នៃជំងឺកូវីដ១៩ សម្រាប់ការបោះឆ្នោតនៅ ២ឆ្នាំ ឬ ៣ឆ្នាំខាងមុខ តើអ្នក [ស្ត្រី] នឹងចូលរួមក្នុងកិច្ចការនយោបាយដែរឬទេ ?

ទោះបីស្ថានភាពនយោបាយមានការផ្លាស់ប្តូរយ៉ាងខ្លាំង ជាពិសេសក្នុងអំឡុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ រួមទាំងការរួមតូចនៃលំហរប្រជាធិបតេយ្យសម្រាប់ពលរដ្ឋ ការបិទប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ការធ្លាក់ចុះនៃការគោរពសិទ្ធិមនុស្ស និងការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលនិងការរំលាយគណបក្សសង្គ្រោះជាតិ ជាពិសេស ការបំភិតបំភ័យ និងការរឹតត្បិតលើអ្នកនយោបាយស្ត្រី និងផលប៉ះពាល់នៃជំងឺកូវីដ១៩ ៨៥.៥%នៃអ្នកចូលរួមការសិក្សាបានឆ្លើយថា ពួកគេនៅតែមានចំណាប់អារម្មណ៍ និងចូលរួមក្នុងនយោបាយ/ការបោះឆ្នោតក្នុងរយៈពេល ២ឆ្នាំ ឬ ៣ ឆ្នាំខាងមុខ (ឆ្នាំ២០២២ និងឆ្នាំ២០២៣)។ ទោះយ៉ាងណា ១៤.៥%នៃអ្នកចូលរួមការសិក្សាបានបញ្ជាក់ថា ពួកគេមិន
</td>
</tr>
</table>

| | |
|---|---|
| | ប្រាកដថាតើពួកគេនឹងបន្តការចូលរួមនយោបាយរបស់ពួកគេឬយ៉ាងណាឡើយ។ អ្នកនយោបាយជាស្ត្រីម្នាក់បានបញ្ជាក់ថា *«ខ្ញុំនៅតែចាប់អារម្មណ៍នឹងនយោបាយ ពីព្រោះខ្ញុំជឿជាក់ថា ការចូលរួមរបស់ខ្ញុំ ក៏ដូចជាការចូលរួមរបស់ស្ត្រីដ៏ទៃទៀតអាចធ្វើឱ្យឋានៈរបស់ស្ត្រីមានភាពល្អប្រសើរនៅក្នុងប្រទេសកម្ពុជាទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ ការគាបសង្កត់នយោបាយ និងអំពើហឹង្សាជាប្រព័ន្ធមានសភាពធ្ងន់ធ្ងរណាស់សព្វថ្ងៃនេះ។ ដូច្នេះ ខ្ញុំចាំបាច់ត្រូវវាយតម្លៃស្ថានភាពឡើងវិញ និងស្វែងរកការគាំទ្របន្ថែមទៀតដើម្បីបន្តការខិតខំប្រឹងប្រែងក្នុងនយោបាយរបស់ខ្ញុំនាពេលអនាគត។»* |

## V. សេចក្តីសន្និដ្ឋាន

ស្ត្រីខ្មែរនៅតែប្រឈមច្រើនទម្រង់នៃការរើសអើង និងអំពើហឹង្សាប្រឆាំងនឹងពួកគេក្នុងការចូលរួម និងផលប្រយោជន៍នយោបាយរបស់ពួកគេ ដែលវាជាបញ្ហាធ្ងន់ធ្ងរទោះបីជាសិទ្ធិនយោបាយ និងការចូលរួមរបស់ស្ត្រីត្រូវបានធានាយ៉ាងពេញលេញដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ក៏ដោយ។ ភាពជាតំណាង និងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីខ្មែរក្នុងវិស័យនយោបាយ និងភាពជាអ្នកដឹកនាំនយោបាយនៅមានកម្រិតទាបនៅឡើយបើប្រៀបធៀបជាមួយសមភាគីបុរសនៅគ្រប់កម្រិត។ ទោះបីយ៉ាងណាក៏ដោយ ៨០% នៃអ្នកចូលរួមក្នុងការស្ទង់មតិបានទទួលស្គាល់ថា ការចូលរួមរបស់ស្ត្រីក្នុងនយោបាយមានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់ការបោះឆ្នោតនៅកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយសមធម៌ និងបរិយាប័ន្នរបស់ប្រទេស។

លទ្ធផលនៃការសិក្សាបង្ហាញពីទិដ្ឋភាពមុខងារនៃការប្រឆាំងអំពើហឹង្សាប្រឆាំងនឹងស្ត្រី បទពិសោធដែលស្ត្រីបានជួបប្រទះជារៀងរាល់ថ្ងៃសម្រាប់ស្ត្រីដែលមានបំណងចូលរួមក្នុងឆាកនយោបាយ។ ការរកឃើញបានបង្ហាញថា ៧១% នៃអ្នកចូលរួមក្នុងការស្រាវជ្រាវបានជួបប្រទះនូវអំពើហឹង្សាប្រឆាំងនឹងស្ត្រី។ ការសិក្សានេះក៏បានបញ្ជាក់ផងដែរថា ស្ត្រីក្នុងឆាកនយោបាយទាំងនៅក្នុងគណបក្សកាន់អំណាច គណបក្សប្រឆាំង និងគណបក្សដ៏ទៃទៀតប្រឈមនឹងអំពើហឹង្សាជាច្រើនទម្រង់ និងកម្រិត។ ទាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងរាស្ត្រស្ត្រីមានបទពិសោធជួបប្រទះអំពើហឹង្សាប្រឆាំងនឹងពួកគេ ប៉ុន្តែទម្រង់ និងកម្រិតខុសគ្នា។ អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សប្រឆាំងគឺគួរឱ្យខ្លាច និងញឹកញាប់ជាងស្ត្រីនៅក្នុងគណបក្សកាន់អំណាច ឬគណបក្សផ្សេងទៀត។ ជាមួយគ្នានេះដែរ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់បានជួបប្រទះនូវការរំលោភបំពាន និងហឹង្សាដោយផ្ទាល់មកលពួកគេជាងអ្នកតំណាងរាស្ត្រស្ត្រី។

ផ្នត់គំនិតរើសអើងយេនឌ័រ អត្តាធិបតេយ្យ បិតាធិបតេយ្យ និងអភិជននិយមនៅតែមានក្នុងគ្រួសារ សហគមន៍ គណបក្សនយោបាយ ភ្នាក់ងារអនុវត្តច្បាប់ និងសាធារណជន។ ទម្រង់ទូទៅបំផុតនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រី គឺ **ការគំរាមកំហែង** និង **អំពើហិង្សាផ្លូវចិត្ត** ត្រូវបានលើកឡើងក្នុងការស្ទង់មតិដោយសកម្មជននយោបាយស្ត្រី សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ (ស្ត្រី និងបុរស) និងអ្នកតំណាងរាស្ត្រ (បុរស និងស្ត្រី)។ ទម្រង់ធ្ងន់ធ្ងរមួយផ្សេងទៀតនៃអំពើហឹងប្រឆាំងនឹងស្ត្រី គឺ **ការរំលោភបំពានលើរាងកាយ** និង**ការយាយីផ្លូវភេទ**ដែលជាក្តីបារម្ភចម្បង ហើយមិនអាចទទួលយកបានជាមួយនឹងអំពើអសីលធម៌ទាំងនេះ ហើយបានផ្ទុយនឹងអនុសញ្ញាស៊ី-ដ និងគោលដៅប្រកបដោយចីរភាព (SDG) ដែលប្រទេសកម្ពុជាបានទទួលយក និងអនុវត្តដើម្បីការពារស្ត្រីពីការរើសអើង និងអំពើហឹង្សា ក៏ដូចជាផ្តល់អំណាចឱ្យស្ត្រី និងក្មេងស្រី។ ស្ត្រីមួយចំនួនដែលបានចូលរួមការស្ទង់មតិ ការពិភាក្សាជាក្រុម និងការសម្ភាសជា

បុគ្គលម្នាក់ៗផ្ទាល់បានជ្រើសរើសយកការរក្សាភាពស្ងៀមស្ងាត់នៅចំពោះមុខការបៀតបៀនផ្លូវភេទ ឬអំពើហិង្សាផ្លូវភេទដោយហេតុផលថាក្នុងបរិបទវប្បធម៌នយោបាយដូចសព្វថ្ងៃ ការប្រកាស ឬការទាមទាររកយុត្តិធម៌ចំពោះករណីបែបនេះនឹងកាន់តែប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ពួកគេនៅក្នុងសង្គម និងឆាកនយោបាយ។ ហេតុនេះ គ្រប់ទម្រង់នៃការរំលោភបំពាន និងអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ គឺជាបញ្ហា និងកង្វល់ចម្បងដែលហាមឃាត់ការចូលរួមដោយសកម្ម និងសក្តានុពលរបស់ស្ត្រីក្នុងឆាកនយោបាយ។

ក្នុងស្ថានភាពជាក់លាក់ អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ (VAWIP)មិនបានទទួលស្គាល់ជាទូទៅទេ។កង្វះការទទួលស្គាល់បាននាំឱ្យមានគម្លាតនៅក្នុងរបាយការណ៍ ការលើកឡើង និងយន្តការឆ្លើយតបដើម្បីគាំទ្រដល់អ្នកចូលរួមជាស្ត្រីក្នុងកិច្ចការនយោបាយ ជាពិសេសអ្នកដែលរស់នៅក្នុងស្ថានភាពសេដ្ឋកិច្ច-សង្គម និងសាវតានយោបាយខុសគ្នា។ លើសពីនេះ អំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ (VAWIP) ជះឥទ្ធិពលអវិជ្ជមានដល់ការចូលរួមស្មើគ្នារបស់ស្ត្រីក្នុងឆាកនយោបាយ ជាពិសេសវាមិនបានលើកទឹកចិត្ត និងបានបំបែកពួកគេពីការចូលរួមក្នុងនយោបាយ។ ផ្លូវសម្រាប់ស្ត្រីដើម្បីក្លាយជាមេដឹកនាំនយោបាយនៅក្នុងគណបក្ស និងជាតំណាងជាប់ឆ្នោត គឺមានការប្រឈមខ្លាំង។ ពួកគេត្រូវការការគាំទ្រ ការផ្តល់សិទ្ធិអំណាច និងឱកាសបន្ថែមទៀតពីរដ្ឋាភិបាល គណបក្សនយោបាយ ស្ថាប័នសាធារណៈ សង្គមស៊ីវិល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)ជាដើម ដើម្បីជំនះឧបសគ្គទាំងឡាយ។

ថ្វីបី ស្ត្រីដែលចូលរួមក្នុងនយោបាយសកម្មជាងគេប្រឈមនឹងការរើសអើង និងអំពើហឹង្សាប្រឆាំងនឹងពួកគេ ផលប៉ះពាល់នៃជំងឺកូវីដ១៩ និងឆាកនយោបាយនៅកម្ពុជាមិនសូវមានលក្ខណៈមេត្រីភាពសម្រាប់ស្ត្រីក្តី ក៏ ៨៥,៥%នៃស្ត្រីដែលបានចូលរួមក្នុងការសិក្សា/ស្ទង់មតិនេះនៅតែចាប់អារម្មណ៍រឿងនយោបាយ ជាពិសេសការបោះឆ្នោតក្នុងរយៈពេល ២ឆ្នាំ ឬ ៣ឆ្នាំខាងមុខនៅឆ្នាំ២០២២ និងឆ្នាំ២០២៣ ហើយពួកគេនៅតែរក្សាឆន្ទៈ និងភាពសកម្មក្នុងការចូលរួម និងការចូលរួមក្នុងកិច្ចការនយោបាយ។

ស្ត្រី និងបុរសខ្មែរត្រូវបានធានាយ៉ាងពេញលេញ និងស្មើភាពគ្នាដោយរដ្ឋធម្មនុញ្ញកម្ពុជាស្តីពី ការចូលរួម និងផលប្រយោជន៍នយោបាយរបស់ពួកគេ។ ទោះយ៉ាងណា លក្ខណៈងាយស្រួលសម្រាប់ស្ត្រី និងបរិយាកាសអំណោយផល (women friendly and enabling environment) គោលនយោបាយ ច្បាប់បោះឆ្នោត និងមាត្រដ្ឋាននៃប្រតិបត្តិការមិនទាន់បានឆ្លើយតបជាក់ស្តែងចំពោះស្ថានភាពនៃការចូលរួមរបស់ស្ត្រីក្នុងឆាកនយោបាយទេ។ គម្លាតនៃគោលនយោបាយ និងច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ មាត្រដ្ឋាននៃប្រតិបត្តិការ និងការវិនិយោគបានពង្រឹងវិសមភាពនៃភាពជាតំណាង និងការចូលរួមរបស់ស្ត្រី។ ដូច្នេះ មានគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្ស និងច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ ហើយត្រូវអនុវត្តបានល្អនឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ស្ត្រីក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងចាប់យកឱកាសស្មើភាពគ្នា ជាបេក្ខជនឈរឈ្មោះ និងជាប់ឆ្នោត ។

## VI. អនុសាសន៍គន្លឹះ

ដើម្បីបង្កើនសមភាពយេនឌ័រ និងផ្តល់អំណាចនយោបាយដល់ស្ត្រី វិធានការខាងក្រោមគួរត្រូវបានដោះស្រាយ៖

### ១. គណបក្សនយោបាយ (Political Party)

- ទទួលស្គាល់នូវតម្រូវការដើម្បីបង្កើតបរិយាកាសនយោបាយប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានសុវត្ថិភាពនៅក្នុងគណបក្សសម្រាប់ស្ត្រី។ ឧទាហរណ៍ដូចជា គោលនយោបាយសមភាពយេនឌ័រ អ្នកទទួលបន្ទុកនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ និងក្រមសីលធម៌ប្រឆាំងអំពើហឹង្សាប្រឆាំងនឹងស្ត្រីនៅក្នុងគណបក្សនីមួយៗ។
- អនុញ្ញាតឱ្យមានការដាក់បញ្ចូលចំនួនសមាជិកគណបក្សជាស្ត្រីឱ្យបានច្រើននៅក្នុងគណៈកម្មាធិការកណ្តាល គណៈកម្មាធិការជ្រើសរើស និងគណៈកម្មាធិការសភា។ ជាមួយគ្នាដែរ ត្រូវផ្សព្វផ្សាយទិន្នន័យ ស្តីពី ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងគណបក្សនយោបាយ។
- បង្កើត និងគោរពច្បាប់ដែលបានអនុម័តដើម្បីប្រយុទ្ធប្រឆាំងអំពើហឹង្សាប្រឆាំងនឹងស្ត្រី។ បន្ថែមលើនេះ បង្កើតយន្តការនានាដើម្បីការពារស្ត្រីពីគ្រប់ទម្រង់នៃអំពើហឹង្សាប្រឆាំងនឹងពួកគេ និងដាក់ទោសទណ្ឌជនល្មើស ព្រមទាំងការពារស្ត្រីនៅពេលពួកគេដាក់ពាក្យបណ្តឹងអំពីអំពើហឹង្សា។
- ជានាបង្កើតគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្សដោយគណបក្សនយោបាយ ហើយគោលនយោបាយនេះត្រូវអនុវត្តឱ្យបានល្អ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីដោយស្មើភាពនៅក្នុងគណបក្សនយោបាយ ដូចជា ស្ត្រីក្នុងដំណើរការបង្កើតគោលនយោបាយ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងតួនាទីជាអ្នកដឹកនាំ ស្ត្រីជាបេក្ខជនឈរឈ្មោះបោះឆ្នោត និងតំណាងស្ត្រីជាប់ឆ្នោត ។ គោលនយោបាយសមភាពយេនឌ័រ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការជំរុញលើកទឹកចិត្តឱ្យគណបក្សនយោបាយទាំងអស់ដាក់បេក្ខភាពស្ត្រីឱ្យបានច្រើននៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស ដោយប្រើប្រព័ន្ធឆ្លាស់គ្នាតាមលំដាប់លេខរៀងពីលើដល់ក្រោមរវាងបេក្ខជនស្ត្រី និងបេក្ខជនបុរស និងបង្កើនសមភាពយេនឌ័រនៅគ្រប់ជាន់ថ្នាក់នៅក្នុងគណបក្សនយោបាយ។

### ២. សភាជាតិ និងព្រឹទ្ធសភា (National Assembly and Senate)

ជានាបង្កើតច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ ទាំងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាវិធានការពិសេសដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើភាពនៅក្នុងវិស័យនយោបាយ និងការអនុវត្តច្បាប់នេះបានល្អ ។ វិធានការពិសេសនេះ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ដែលអាចជម្រុញលើកទឹកចិត្តគ្រប់គណបក្សនយោបាយដាក់បេក្ខភាពស្ត្រីច្រើននៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស។ ការលើកទឹកចិត្តដើម្បីអនុវត្តរបស់គណបក្សនយោបាយនេះ គឺត្រូវ

បង្កើតក្នុងក្របខណ្ឌច្បាប់ គឺនិយាយដល់ការធ្វើវិសោធនកម្មច្បាប់សម្រាប់ការបោះឆ្នោត ។ វិសោធកម្មច្បាប់នេះ កែលម្អបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឲ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើ ដល់ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ។ ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដូចជា ច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជំពូកទី៤ មាត្រា២៧ និងមាត្រា២៨ «***បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលនីមួយៗ ត្រូវមានបេក្ខជនស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នាតាមលំដាប់លេខរៀងពីលើដល់ក្រោម***» និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជំពូកទី៦ មាត្រា៣៩ «***បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពីលើដល់ក្រោម***» ។

## ៣. ស្ថាប័នរដ្ឋ និងស្ថាប័នសាធារណៈ (State and Public Institutions)

- រៀបចំរចនាសម្ព័ន្ធ និងបង្កើតគោលនយោបាយ និងច្បាប់ដែលប្រឆាំងអំពើហឹង្សាប្រឆាំងនឹងស្ត្រីក្នុងកិច្ចការនយោបាយ។ បង្កើតស្ថាប័នសង្កេតការណ៍ឯករាជ្យមួយដែលកំណត់អំពើហឹង្សាលើស្ត្រីក្នុងវិស័យនយោបាយ និងធ្វើរបាយការណ៍ជាទៀងទាត់អំពីព័ត៌មានទាំងនេះដល់អ្នកពាក់ព័ន្ធ និងសាធារណជន។
- រដ្ឋាភិបាល (ក្រសួងពាក់ព័ន្ធ) គួរផ្តល់ការគាំទ្រគ្រប់បែបយ៉ាងដូចជា ថវិកា ធនធាននានា និងធនធានមនុស្សដល់អ្នកដឹកនាំស្ត្រី និងស្ត្រីជាប់ឆ្នោត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើនប្រសិទ្ធភាព និងគុណភាពនៃការចូលរួមនយោបាយ ការងារ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី។
- រាជរដ្ឋាភិបាលកម្ពុជាត្រូវពិនិត្យមើលឡើងវិញ និងយកចិត្តទុកដាក់បន្ថែមចំពោះអ្នកនយោបាយស្ត្រីនៅក្នុងគណបក្សដែលខ្លួនកំពុងដឹកនាំរដ្ឋាភិបាល ឬក៏អ្នកនយោបាយស្ត្រីគណបក្សផ្សេងៗដែលមានសម្លេង និងសកម្ម ឬស្ត្រីដែលបំរុងនឹងចូលរួមក្នុងវិស័យនយោបាយ ដោយលើកទឹកចិត្ត ការពារ ផ្តល់ឱកាសស្មើគ្នា និងធានាឲ្យបាននូវការចូលរួមដោយពេញលេញក្នុងកិច្ចការនយោបាយរបស់ស្ត្រី។
- រាជរដ្ឋាបាលកម្ពុជាត្រូវពង្រឹងការគោរពសិទ្ធិនយោបាយរបស់ស្ត្រី និងធានាឱ្យបានក្នុងការអនុវត្តសិទ្ធិនេះដោយបង្កលក្ខណៈងាយស្រួលដល់ស្ត្រីធ្វើការជួបជជែកគ្នាអំពីកិច្ចការនយោបាយ និងកិច្ចការផ្សេងៗ ជាពិសេសសម្រាប់អ្នកនយោបាយស្ត្រីដែលមកពីគណបក្សប្រឆាំង និងគណបក្សផ្សេងទៀត ប្រយោជន៍គាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមកាន់តែច្រើនក្នុងកិច្ចការនយោបាយ និងថ្នាក់សម្រេចចិត្ត ស្របតាមអនុសញ្ញាស៊ី-ដ (CEDAW) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDG)។

- ក្រសួងមហាផ្ទៃ និងអាជ្ញាធរពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវជានាចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ជាពិសេសស្ត្រីទទួលបាននូវតួនាទីភារកិច្ច និងសិទ្ធិអំណាចពេញលេញស្របតាមច្បាប់ស្តីពី «ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់» និងអនុសញ្ញាស៊ី-ដ។ ឧទាហរណ៍ ការបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃដើម្បីត្រួតពិនិត្យលក្ខខណ្ឌការងារ និងបញ្ហាប្រឈមរបស់ពួកគេ ។

## ៤. អង្គការសង្គមស៊ីវិល វិទ្យាស្ថានអប់រំ និងការសិក្សា (CSOs, Educational Institutions and Academies)

- បង្កើនយន្តការគាំទ្រសម្រាប់អ្នកនយោបាយស្ត្រីដូចជា ការអភិវឌ្ឍសមត្ថភាព (ទំនុកចិត្តលើខ្លួនឯង និងជំនាញដែលចាំបាច់ដើម្បីចូលរួមក្នុងនយោបាយ រួមមាន ការបង្កើតយុទ្ធសាស្ត្របញ្ចុះបញ្ចូល និងយុទ្ធនាការឃោសនាប្រកបដោយប្រសិទ្ធភាព) ការផ្តល់អំណាច និងមូនិធិនយោបាយពិសេសដល់ស្ត្រីក្នុងវិស័យនយោបាយ។
- បង្កើនការស្រាវជ្រាវសិក្សា ការជជែកវែកញែក និងការពិភាក្សាអំពីអំពើហិង្សាប្រឆាំងនឹងស្ត្រី និងភាពជាអ្នកដឹកនាំនយោបាយរបស់ស្ត្រី និងជួយសម្របសម្រួលដល់ការតុបតែងសម្ផិតសម្អាងនយោបាយនៃអ្នកនយោបាយស្ត្រីដែលមានសក្តានុពល ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីផលប៉ះពាល់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយទៅលើស្ត្រី និងសង្គមទាំងមូល។
- បង្កើនការអប់រំពលរដ្ឋ និងនយោបាយនៅកម្ពុជា (ការអភិវឌ្ឍសមត្ថភាព និងជំនាញ របៀបចូលក្នុងនយោបាយ និងការផ្លាស់ប្តូរផ្នត់គំនិត) ដើម្បីផ្លាស់ប្តូររបៀបដែលសង្គមកម្ពុជាយល់ពីនយោបាយ រួមទាំង តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងវិស័យនយោបាយ និងការគាំទ្រពួកគាត់។
- ប្រើប្រាស់ទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម និងប្រព័ន្ធផ្សព្វផ្សាយដើម្បីធ្វើយុទ្ធនាការអំពីសិទ្ធិស្ត្រីដោយសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការចូលរួមក្នុងនយោបាយ និងតួនាទីជាអ្នកដឹកនាំរបស់ស្ត្រី ។
- បន្តពន្លឿនការលុបបំបាត់ភាពខុសគ្នាផ្នែកយេនឌ័រនៅកម្រិតសាធារណៈ និងគ្រួសារ ។

## ៥. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (National Election Committee-NEC)

ជានាបង្កើតបទបញ្ញា និងនីតិវិធីដែលឆ្លើយតបនឹងយេនឌ័ររបស់គ.ជ.បសម្រាប់ការបោះឆ្នោតដើម្បីបង្កើនសមភាពយេនឌ័រ និងផ្តល់ឱកាសស្មើភាពដល់បេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតដោយបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឱ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ។